# សុន្ទរកថា

# របស់

# ឯកឧត្តម ប៊ិន ឈិន ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីស្តីទី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី តំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

# ក្នុង

# ពិធីបើកកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីទូរគមនាគមន៍ និងព័ត៌មានវិទ្យាអាស៊ានលើកទី១៧ និងកិច្ចប្រជុំពាក់ព័ន្ធ

*ខេត្តសៀមរាប ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៧*

*(វេលាម៉ោង ៩:០០-១០:០០ ព្រឹក)*

- *ឯកឧត្តមរដ្ឋមន្ត្រីទូរគមនាគមន៍ និងព័ត៌មានវិទ្យាអាស៊ាន*
- *ឯកឧត្តមអគ្គលេខាធិការដ្ឋានអាស៊ាន*
- *ឯកឧត្តម លោកជំទាវគណៈប្រតិភូ ភ្ញៀវជាតិ និងអន្តរជាតិ*
- *លោក លោកស្រី នាងកញ្ញាជាទីមេត្រី!*

ជាបឋម ក្នុងនាម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ខ្ញុំសូមសម្តែងនូវកិច្ចស្វាគមន៍យ៉ាងកក់ក្តៅជូនចំពោះឯកឧត្តមរដ្ឋមន្ត្រីអាស៊ាន ឯកឧត្តមអគ្គលេខាធិការដ្ឋានអាស៊ាន ឯកឧត្តម លោកជំទាវគណៈប្រតិភូនៃបណ្តាប្រទេសអាស៊ាន ព្រមទាំងភ្ញៀវកិត្តិយសជាតិនិងអន្តរជាតិទាំងអស់ ដែលបានអញ្ជើញចូលរួមកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីទូរគមនាគមន៍ និងព័ត៌មានវិទ្យាអាស៊ានលើកទី១៧ និងកិច្ចប្រជុំពាក់ព័ន្ធ រួមមានកិច្ចប្រជុំអមរបស់វិស័យឯកជន ដែលបានរៀបចំឡើងនៅក្នុងខេត្តសៀមរាប ដែនដីដ៏ចំណាស់មួយនៃតំបន់អង្គរ។ ព្រះរាជាណាចក្រកម្ពុជា មានកិត្តិយសធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំដ៏មានសារៈសំខាន់បំផុតនេះ ម្យ៉ាងស្របពេលនឹងការ

ប្រារព្ធ **ខួបទី ៥០ ឆ្នាំ នៃការបង្កើតអាស៊ាន** និងម្យ៉ាងទៀតជាការបន្តកិច្ចខិតខំប្រឹងប្រែងរួមគ្នា ដើម្បីឈានទៅរកការសម្រេចឱ្យបាននូវចក្ខុវិស័យសហគមន៍អាស៊ានឆ្នាំ២០២៥។

បន្ទាប់ពីមានការអភិវឌ្ឍក្នុងអំឡុងពេលប្រាំទសវត្សរ៍កន្លងមក អាស៊ានបានឆ្លងកាត់នូវការផ្លាស់ប្តូរយ៉ាងខ្លាំង ដោយបានប្រែក្លាយអាស៊ានពីតំបន់គ្មានស្ថេរភាពពេញលេញ ទៅជាតំបន់ប្រកបទៅដោយសន្តិភាព សន្តិសុខ ស្ថេរភាព និងការអភិវឌ្ឍ។ បច្ចុប្បន្ននេះ អាស៊ានបានក្លាយជាស្ថាប័ននៃសមាហរណកម្មសេដ្ឋកិច្ចនិងនយោបាយដ៏ជិតស្និទមួយ។ អាស៊ានគឺជាស្ថាប័នដ៏មានឥទ្ធិពលមួយនៅអាស៊ីនិងជាដៃគូយុទ្ធសាស្ត្រមិនអាចខ្វះបាននៃបណ្តាប្រទេសនិងអង្គការធំៗក្នុងពិភពលោកផងដែរ។ ព្រះរាជាណាចក្រកម្ពុជាពិតជាមានមោទនភាពជាខ្លាំង ដោយបានរួមចំណែកជាវិជ្ជមានចំពោះអាស៊ាន ស្របតាមសមត្ថភាព និងលទ្ធភាពរបស់ខ្លួន ក្នុងការនាំមកនូវដំណើរការវិវត្តន៍ដូចនេះ ចាប់តាំងពីកម្ពុជាបានក្លាយជាសមាជិកពេញសិទ្ធិរបស់អាស៊ាន។ ឆ្លៀតក្នុងឱកាសដ៏មានតម្លៃនេះ ខ្ញុំសូមថ្លែងអំណរគុណចំពោះប្រទេសហ្វីលីពីនសម្រាប់ការបំពេញភារកិច្ចដោយជោគជ័យជាប្រធានអាស៊ានក្នុងឆ្នាំនេះ និងសូមចូលរួមអបអរសាទរចំពោះប្រទេសសឹង្ហបុរីដែលនឹងមកទទួលភារកិច្ចជាប្រធានអាស៊ាននៅឆ្នាំក្រោយ។ ក្នុងនាមជាសមាជិកប្រកបដោយបុរេសកម្មរបស់អាស៊ាន ព្រះរាជាណាចក្រកម្ពុជា នឹងខិតខំប្រឹងប្រែងអស់ពីសមត្ថភាព ក្នុងការសហការយ៉ាងជិតស្និទជាមួយរដ្ឋជាសមាជិកអាស៊ានផ្សេងទៀត ដើម្បីសម្រេចបាននូវអាទិភាពផ្សេងៗរបស់អាស៊ានឆ្ពោះទៅកាន់ការសម្រេចបាននូវ "**ចក្ខុវិស័យសហគមន៍អាស៊ានឆ្នាំ២០២៥**"។

***ឯកឧត្តម លោកជំទាវ លោក លោកស្រី***

វិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន គឺជាកាតាលីករក្នុងការជំរុញការអភិវឌ្ឍយ៉ាងឆាប់រហ័សនៃអ៊ិនធឺណិតចល័តនិងបណ្តាញគមនាគមន៍ចល័ត។ វិស័យនេះបានជំរុញឱ្យមានការផ្លាស់ប្តូរជាខ្លាំងដោយមិនអាចប្រកែកបាន និងត្រូវបានប្រើប្រាស់ជាមធ្យោបាយសម្រាប់ការចែករំលែកចំណេះដឹងគ្រប់ផ្នែកទាំងអស់ក្នុងជីវិតរស់នៅរបស់មនុស្ស។ វិស័យនេះក៏បានក្លាយជាទិដ្ឋភាពស្នូលមួយនៃបណ្តាទិដ្ឋភាពទាំងឡាយក្នុងជីវិតរបស់យើងគ្រប់គ្នា រួមទាំងផ្នែកនយោបាយ សកម្មភាពសេដ្ឋកិច្ចនិងទំនាក់ទំនងអន្តរកម្មសង្គម។ល។ ការសម្រេចបាននូវសង្គមព័ត៌មាននិងសេដ្ឋកិច្ចពុទ្ធិនេះ គឺជាអាទិភាពចម្បងមួយក្នុងចំណោមបណ្តាអាទិភាពទាំងឡាយរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងដំណើរឆ្ពោះទៅកាន់ការសម្រេចគោលបំណងនៃការអភិវឌ្ឍប្រកបដោយចីរភាព។

ទិន្នន័យចុងក្រោយបង្អស់របស់សហភាពទូរគមនាគមន៍អន្តរជាតិ (ITU) បង្ហាញថា អ្នកជាវសេវាទូរស័ព្ទចល័តមានចំនួនច្រើនជាងចំនួនប្រជាជនរបស់ពិភពលោក។ ចំនួនអ្នកជាវសេវាទូរស័ព្ទចល័តនឹងកើនឡើងដល់ប្រមាណ ៧,៧ ពាន់លាននាក់ ត្រឹមចុងឆ្នាំ២០១៧ ស្មើនឹងអត្រាប្រើប្រាស់ចំនួន ១០៣.៥% ដែលក្នុងនេះចំនួនច្រើនជាងពាក់កណ្តាល (៤,២ ពាន់លាននាក់) ស្ថិតនៅក្នុងតំបន់អាស៊ី-

ប៉ាស៊ីហ្វិក។ ជាងនេះទៅទៀត ប្រជាជនចំនួន ៣,៦ ពាន់លាននាក់ នឹងមានសេវាអ៊ិនធឺណិតប្រើប្រាស់ នៅត្រឹមដំណាច់ឆ្នាំ២០១៧ ស្មើនឹងចំនួនប្រមាណ ៤៨% នៃចំនួនប្រជាជនរបស់ពិភពលោក។ ជាមួយគ្នានេះដែរ គិតត្រឹមដំណាច់ឆ្នាំ២០១៧នេះ អត្រាគ្រួសារដែលប្រើប្រាស់សេវាអ៊ិនធឺណិតនៅលើពិភពលោក នឹងមានចំនួន ៥៣,៦%។ គ្រួសារចំនួន ៤៣% នៃប្រទេសកំពុងអភិវឌ្ឍនឹងត្រូវបានភ្ជាប់សេវាអ៊ិនធឺណិត ដោយប្រៀបធៀបជាមួយនឹងអត្រាគ្រួសារនៃប្រទេសអភិវឌ្ឍគឺមានចំនួន ៨៤,៤%។ នៅកម្ពុជា ចំនួនអ្នកជាវសេវាទូរស័ព្ទចល័តនឹងកើតឡើងដល់ចំនួនប្រមាណ ១៩ លាន ត្រឹមដំណាច់ឆ្នាំ២០១៧ ដែលគ្របដណ្តប់នៅទីប្រជុំជនចំនួន ១០០%។ អត្រានៃការជាវសេវាទូរស័ព្ទចល័តមានចំនួនប្រមាណ ១២៥% នៃចំនួនប្រជាជនសរុប។ ចំនួននៃការជាវសេវាអ៊ិនធឺណិតនឹងកើនដល់ចំនួន ៨,៥ លាននាក់ ត្រឹមចុងឆ្នាំ ២០១៧ ស្មើនឹងអត្រាប្រើប្រាស់ប្រមាណ ៦០%។ ប្រជាជនដែលមិនទាន់ត្រូវបានតភ្ជាប់ភាគច្រើនរស់នៅតាមតំបន់ជនបទនិងដាច់ស្រយាល។ ដើម្បីធ្វើការតភ្ជាប់ជូនពួកគេ យើងទាំងអស់គ្នានៅទីនេះត្រូវខិតខំប្រឹងប្រែងទាំងអស់គ្នា។ ហេតុដូច្នេះ ការបង្កើតបរិស្ថានប្រកបដោយភាពទាក់ទាញសម្រាប់ការវិនិយោគបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន នឹងក្លាយជាអាទិភាពចម្បងមួយនៃបណ្តាអាទិភាពជាចម្បងនានារបស់យើង។

បច្ចេកវិទ្យាជំនាន់ទី៤ (4G/LTE) ត្រូវបានដាក់ឱ្យដំណើរការនៅរាជធានី ខេត្តទាំង២៥ និងគ្របដណ្តប់ផ្ទៃដីស្មើរតែ ៦០% នៃផ្ទៃដីប្រទេសកម្ពុជាទាំងមូល។ បច្ចេកវិទ្យាកម្រិតខ្ពស់ 4.5G/LTE advanced ត្រូវបានប្រកាសដាក់ឱ្យដំណើរការនាពេលថ្មីៗនេះ ដែលអនុញ្ញាតឱ្យយុវជនយើងរីករាយជាមួយការប្រើប្រាស់សេវាអ៊ិនធឺណិតល្បឿនលឿននិងតម្លៃទាបបំផុតនៅក្នុងតំបន់។ ទោះបីជាយ៉ាងនេះក៏ដោយ យើងនូវតែខិតខំពង្រឹងការប្រកួតប្រជែងផ្នែកសេវាអ៊ិនធឺណិត និងសេវាទូរស័ព្ទចល័តនៅកម្ពុជា ជាពិសេសពាក់ព័ន្ធនឹងគុណភាពនៃសេវា ដោយប្រៀបធៀបជាមួយនឹងបណ្តាប្រទេសជិតខាងក្នុងតំបន់តែម្តង។

រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់អំពីការវិវត្តន៍បច្ចេកវិទ្យាយ៉ាងឆាប់រហ័សនេះ ក៏ដូចជានិន្នាការទីផ្សារនិងសេដ្ឋកិច្ចក្នុងវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ហេតុដូច្នេះហើយបានជារាជរដ្ឋាភិបាលកម្ពុជាបានបន្តអភិវឌ្ឍបន្ថែមលើវិស័យទូរគមនាគមន៍-បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ជាសេវាទំនើប និងគុណភាពខ្ពស់ ស្របតាមស្តង់ដាអន្តរជាតិ ការប្រកួតប្រជែងខ្ពស់ និងការគ្របដណ្តប់ទូទាំងផ្ទៃប្រទេស។ ដូចនេះ ប្រជាជនទូទៅនឹងអាចមានលទ្ធភាពប្រើប្រាស់ និងទទួលអត្ថប្រយោជន៍ពីសេវាទាំងអស់នេះ។ ជាមួយគ្នានេះដែរ ឆ្លៀតឱកាសនេះ ខ្ញុំសូមអនុញ្ញាតធ្វើការចែករំលែកអំពីសមិទ្ធិផលពាក់ព័ន្ធខ្លះៗរបស់កម្ពុជាដូចខាងក្រោមៈ

***ទី១.*** បន្ទាប់ពីការរួមបញ្ចូលគ្នានៃវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានឱ្យស្ថិតនៅក្រោមដំបូលតែមួយនិងមានការរចនាសម្ព័ន្ធគ្រប់គ្រងថ្មី ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍បានសម្រេចនូវសមិទ្ធិផលជាច្រើនគួរកត់សម្គាល់ ក្នុងរយៈពេល ០៤ ឆ្នាំនេះ ក្នុងការកសាងនូវសេវាទូរគមនាគមន៍ប្រកបដោយទូលាយនិងមានតម្លៃសមរម្យ ជាពិសេសក្នុងវិស័យទូរស័ព្ទចល័តនិង បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន។ ការរៀបចំបទប្បញ្ញត្តិនិងគោលនយោបាយផ្ដោតលើការគាំទ្រសហគ្រាសគឺជាសសរស្ដម្ភមួយនៃការរីកចម្រើននេះ។ ការបង្កើតភាពជាដៃគូមានការទុកចិត្តជាមួយឧស្សាហកម្មទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន និងការផ្ដល់សេវាដល់សហគមន៍អ្នកប្រើប្រាស់គឺជាសសរស្ដម្ភមួយផ្សេងទៀត។ ជាលទ្ធផល ផែនការមេបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានរបស់កម្ពុជាឆ្នាំ២០២០ និងគោលនយោបាយអភិវឌ្ឍន៍វិស័យទូរគមនាគមន៍-បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានឆ្នាំ២០២០ ត្រូវបានប្រកាសឱ្យប្រើជាផ្លូវការនៅខែសីហា ឆ្នាំ២០១៤ និងនៅខែមេសា ឆ្នាំ២០១៦ ជាបន្តបន្ទាប់។ ផែនការមេបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានរបស់កម្ពុជាឆ្នាំ២០២០ បានកំណត់និងដាក់ចេញនូវគម្រោងអាទិភាពចំនួនប្រាំ រួមមាន ក្របខណ្ឌរដ្ឋាភិបាលអេឡិកត្រូនិកដែលត្រូវបានអនុវត្តតាំងពីឆ្នាំ២០០៤, សន្តិសុខបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ការអប់រំតាមប្រព័ន្ធអេឡិកត្រូនិក ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិកត្រូនិក និងទេសចរណ៍តាមប្រព័ន្ធអេឡិកត្រូនិក។ ទន្ទឹមនឹងចក្ខុវិស័យដ៏ត្រឹមត្រូវនិងច្បាស់លាស់នៃការប្រែក្លាយកម្ពុជាទៅជាសង្គមដែលមានសន្និភាព និងកម្មញ្ញភាពលើវិស័យទូរគមនាគមន៍-បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន, គោលនយោបាយអភិវឌ្ឍន៍វិស័យទូរគមនាគមន៍-បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ឆ្នាំ២០២០ មានគោលបំណងពង្រឹងនិងពង្រីកការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍-បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ការជំរុញការអភិវឌ្ឍធនធានមនុស្ស និងការលើកកម្ពស់ឧស្សាហកម្មនិងការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន។

ជាងនេះទៅទៀត ដើម្បីត្រួតពិនិត្យមើលទិដ្ឋភាពបច្ចេកទេសលើវិស័យទូរគមនាគមន៍ និយ័តករទូរគមនាគមន៍កម្ពុជា (ន.ទ.ក.) ត្រូវបានធ្វើកំណែទម្រង់នាពេលថ្មីៗ ស្របតាមច្បាប់ស្ដីពីទូរគមនាគមន៍ដែលត្រូវបានប្រកាសឱ្យប្រើនៅខែធ្នូ ឆ្នាំ២០១៥ ដែលមានសង្គតិភាពជាមួយការប្ដេជ្ញាចិត្តរបស់កម្ពុជាចំពោះអង្គការពាណិជ្ជកម្មពិភពលោក និងគោលការណ៍ណែនាំនៃការរៀបចំបទប្បញ្ញត្តិរបស់សហភាពទូរគមនាគមន៍អន្តរជាតិ (ITU)។ ច្បាប់ស្ដីពីទូរគមនាគមន៍មានគោលបំណងធានាការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធនិងបណ្ដាញ និងការផ្ដល់សេវាទូរគមនាគមន៍ប្រកបដោយប្រសិទ្ធភាព សុវត្ថិភាព ភាពអាចទុកចិត្តបាន ភាពដែលអាចទទួលយកបាន និងគុណភាពខ្ពស់, ធានាការលើកទឹកចិត្តដល់ការវិនិយោគរបស់វិស័យឯកជន និងការប្រកួតប្រជែងស្របច្បាប់ និងធានាការការពារអ្នកប្រើប្រាស់។

គោលនយោបាយនិងផែនការយុទ្ធសាស្ត្រជាច្រើនទៀតត្រូវបាននិងកំពុងរៀបចំឡើង ដើម្បីធ្វើជាសរសស្ដម្ភគាំទ្រ ក្នុងការប្រែក្លាយសេដ្ឋកិច្ចកម្ពុជាទៅជាសេដ្ឋកិច្ចឌីជីថល នៅឆ្នាំ២០២៣ ដូចជាផែនការ

យុទ្ធសាស្ត្ររដ្ឋាភិបាលអេឡិកត្រូនិកកម្ពុជា ដែលរួមបញ្ចូលនូវក្របខណ្ឌនិម្មាបនកម្មនិងស្តង់ដា, គោលនយោបាយស្តីពីការបង្កើតអាជីវកម្មថ្មី (StartUp) គោលនយោបាយសហគ្រាសខ្នាតតូចនិងមធ្យមឌីជីថល និងគោលនយោបាយមីក្រូសហគ្រាសខ្នាតតូចនិងមធ្យមឌីជីថល និងផែនការយុទ្ធសាស្ត្រសម្រាប់ FinTech ។ល។

***ទី២.*** កម្ពុជាប្តេជ្ញាធ្វើការតភ្ជាប់គ្រប់ទីកន្លែងនៅទូទាំងប្រទេស និងធានាថាអត្ថប្រយោជន៍នៃបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានបានទៅដល់តំបន់ដាច់ស្រយាលទាំងអស់ ក៏ដូចជាសហគមន៍ងាយរងគ្រោះផងដែរ។ បណ្តាញនិងសេវាដែលគ្របដណ្តប់ដោយខ្សែកាប្លិ៍អុបទិកត្រូវបានពង្រីកជាបន្តបន្ទាប់ មានប្រវែងជាង ២៨,០០០ គីឡូម៉ែត្រ ដោយធ្វើការតភ្ជាប់ពីរាជធានីភ្នំពេញទៅកាន់គ្រប់ស្រុកទាំងអស់នៅទូទាំងប្រទេស គិតត្រឹមឆ្នាំ២០១៨។ ឆ្នាំនេះជាប្រវត្តិសាស្ត្រមួយរបស់កម្ពុជាដែលសម្រេចបាននូវហេដ្ឋារចនាសម្ព័ន្ធបណ្តាញខ្សែកាប្លិ៍អុបទិកក្រោមបាតសមុទ្រចំនួនពីរ។ បណ្តាញខ្សែកាប្លិ៍ក្រោមបាតសមុទ្រទីមួយឈ្មោះ MCT (ម៉ាឡេស៊ី កម្ពុជា ថៃឡង់ដ៍) វិនិយោគដោយក្រុមហ៊ុន Telcotech ដែលជាបណ្តាញខ្សែកាប្លិ៍អុបទិកក្រោមបាតសមុទ្រកម្រិតតំបន់។ បណ្តាញខ្សែកាប្លិ៍អុបទិកមួយទៀតឈ្មោះ AAE-1 (អាស៊ី-អាហ្វ្រិក-អឺរ៉ុប) វិនិយោគដោយក្រុមហ៊ុន Heyroute ដែលជាក្រុមហ៊ុនមេរបស់ក្រុមហ៊ុន CFOCN។ បណ្តាញខ្សែកាប្លិ៍ក្រោមបាតសមុទ្រមួយនេះគឺជាបណ្តាញខ្សែកាប្លិ៍ក្រោមបាតសមុទ្រអន្តរទ្វីបលើកដំបូង និងជាប្រវត្តិសាស្ត្ររបស់កម្ពុជា។ ជាមួយគ្នានេះដែរ ខ្ញុំពិតជាមានសេចក្តីរីករាយជាខ្លាំងដែលធ្វើជាអធិបតីក្នុងពិធីសម្ពោធបើកឱ្យដំណើរការខ្សែកាប្លិ៍អុបទិកក្រោមបាតសមុទ្រ អាស៊ី អាហ្វ្រិក អឺរ៉ុប (AAE-1) បន្ទាប់ពីពិធីបើកកិច្ចប្រជុំនេះ។

***ទី៣.*** រាជរដ្ឋាភិបាលកម្ពុជាក៏បានប្តេជ្ញាចិត្តពង្រីកការចូលប្រើប្រាស់ទៅដល់គ្រប់ជ្រុងទាំងអស់នៃសង្គមផងដែរ ដើម្បីធានាថាសេដ្ឋកិច្ចឌីជីថលអាចនឹងផ្តល់អត្ថប្រយោជន៍ស្មើគ្នាចំពោះប្រជាជនយើង។ ជាលទ្ធផល នាពេលថ្មីៗនេះ រាជរដ្ឋាភិបាលបានអនុម័តអនុក្រឹត្យស្តីពីការកំណត់យន្តការសម្រាប់ការអនុវត្តកម្មវិធីកាតព្វកិច្ចសេវាសកលវិស័យទូរគមនាគមន៍ ដែលជាយន្តការសកលមួយសម្រាប់កាត់បន្ថយគម្លាតឌីជីថល និងជួយដល់តំបន់ដែលគ្មានតម្លៃសេដ្ឋកិច្ចនៅក្នុងកាលៈទេសៈធម្មតា ដើម្បីកសាងហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ និងកសាងកម្មវិធីនិងមាតិកាពាក់ព័ន្ធផ្សេងៗ។ សំខាន់ជាងនេះ និងគួរឱ្យរំភើបរីករាយទៀតនោះ ដោយសារការវិវត្តន៍យ៉ាងឆាប់រហ័សនៃទូរស័ព្ទចល័ត បច្ចេកវិទ្យាចុងក្រោយបំផុតនឹងផ្តល់ជូនទៅដល់ប្រជាជនកម្ពុជារាប់លាននាក់ដែលរស់នៅតំបន់ជនបទទាំងនោះ ដែលអនុញ្ញាតឱ្យពួកគាត់អាចប្រើប្រាស់អ៊ិនធឺណិតចល័ត និងបង្កើនការចូលប្រើប្រាស់ព័ត៌មានយ៉ាងទូលំទូលាយ។ ជាចក្ខុវិស័យដ៏ទូលំទូលាយរបស់រាជរដ្ឋាភិបាលកម្ពុជា យើងបានកំណត់គោលដៅសម្រាប់ឆ្នាំ២០២០ ក្នុងការពង្រីកវិសាលភាពសេវាអ៊ិនធឺណិតល្បឿនលឿនគ្របដណ្តប់ទីប្រជុំជនដល់ ១០០% និងទីជនបទដល់ ៧០% ការប្រើប្រាស់សេវាអ៊ិនធឺណិតដល់ ៨០% ការតភ្ជាប់អ៊ិនធឺណិតនៃវត្ថុឬតភ្ជាប់ឧបករណ៍នឹងបណ្តាញដល់ ១០%

និងគោលដៅផ្សេងទៀតដូចដែលត្រូវបានកំណត់នៅក្នុងគោលនយោបាយអភិវឌ្ឍន៍វិស័យទូរគមនាគមន៍-បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានឆ្នាំ២០២០។

***ទី៤.*** ខណៈពេលដែលទស្សនៈវិស័យលើវិស័យនេះហាក់មានភាពជាវិជ្ជមាននិងជាទីពេញចិត្ត យើងក៏ត្រូវតែទទួលស្គាល់ថា យើងនៅមានការងារជាច្រើនទៀតត្រូវបន្តធ្វើ ជាពិសេសពាក់ព័ន្ធនឹងគុណភាព និងលំដាប់នៃឱកាសសម្រាប់ការអប់រំ និងគម្លាតជំនាញបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន នៅតែជាបញ្ហាប្រឈមនៅឡើយ។ គួរយ៉ាង ការងារគ្រប់គ្រង ការងារបច្ចេកទេស និងបណ្តាញ នៅក្នុងអនុវិស័យទូរគមនាគមន៍ចល័តដែលអភិវឌ្ឍយ៉ាងឆាប់រហ័សនេះ គឺស្ថិតនៅក្នុងការគ្រប់គ្រងដោយជនជាតិបរទេស។ និន្នាការនេះពុំមែនមានតែនៅកម្ពុជានោះទេ ប៉ុន្តែជានិន្នាការនៅក្នុងតំបន់ផងដែរ។ ការផ្តល់ពិន្ទុសម្រាប់ភាពរួចរាល់ផ្នែកបច្ចេកទេសរបស់យើងគឺនៅទាបនៅឡើយ ហើយដែលគោលនយោបាយអភិវឌ្ឍន៍វិស័យទូរគមនាគមន៍-បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានឆ្នាំ២០២០ និងគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មឆ្នាំ២០២៥ ប្រមូលផ្តុំទាំងរដ្ឋាភិបាល វិស័យឯកជន និងអង្គការអន្តរជាតិ ដើម្បីធានាការប្រើប្រាស់សេវាអ៊ីនធឺណិតល្បឿនលឿន និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន អាចទទួលយកបាន ដែលប្រែក្លាយកម្ពុជាទៅជាប្រទេសមានមូលដ្ឋានសេដ្ឋកិច្ចពុទ្ធិ។

ហេតុដូចនេះ វិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានថ្មីមួយត្រូវបានបង្កើតនៅដើមឆ្នាំ២០១៤។ វិទ្យាស្ថានជាតិនេះបង្កើតឡើងក្នុងគោលបំណងបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ និងទាញយកអត្ថប្រយោជន៍ជាអតិបរមាពីបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ដោយធ្វើការពង្រឹងកម្មវិធីសិក្សាគ្រប់កម្រិត ការបណ្តុះបណ្តាលមន្ត្រីរាជការ និងការលើកទឹកចិត្តវិស័យឯកជនឱ្យចូលរួមលើកកម្ពស់អក្ខរកម្មសាធារណៈក្នុងវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន។ ការស្រាវជ្រាវនិងការអភិវឌ្ឍក្នុងវិស័យនេះត្រូវបានលើកកម្ពស់ជាបន្តបន្ទាប់ រួមមានការណែនាំសម្រាប់ការស្រាវជ្រាវគម្រូបណ្តាញតភ្ជាប់ទៅនឹងសាកលវិទ្យាល័យ រដ្ឋាភិបាល និងឧស្សាហកម្ម។ ជាការពិត រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់ពីភាពចាំបាច់ក្នុងការបង្កើតបរិយាកាសដែលគាំទ្រដល់នវានុវត្តន៍និងការវិនិយោគ។ ដើម្បីសម្រេចបានដូច្នេះ រាជរដ្ឋាភិបាលកម្ពុជា ក៏បានអនុម័តអនុក្រឹត្យស្តីពីការកំណត់យន្តការសម្រាប់គ្រប់គ្រងផែនការកសាងសមត្ថភាពនិងការស្រាវជ្រាវនិងការអភិវឌ្ឍវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ដើម្បីបម្រើជាក្របខណ្ឌបទប្បញ្ញត្តិក្នុងការដោះស្រាយបញ្ហាប្រឈមនានា។

## *ឯកឧត្តម លោកជំទាវ លោក លោកស្រី*

ជាមូលដ្ឋាន អនាគតនៃតំបន់របស់យើងត្រូវបានបញ្ចូលគ្នាតាមរយៈបច្ចេកវិទ្យាឌីជីថល ដូចនេះ យើងត្រូវធ្វើការរួមគ្នាដើម្បីផ្លាស់ប្តូររដ្ឋសមាជិកអាស៊ាន និងប្រជាជនអាស៊ានទាំងអស់ទៅជាសហគមន៍ឌីជីថល ដែលផ្អែកលើភាពចាំបាច់នៃប្រព័ន្ធព័ត៌មានអេឡិកត្រូនិក តាមរយៈការអភិវឌ្ឍសេវានិងហេដ្ឋា-

រចនាសម្ព័ន្ធ។ ដោយហេតុដូចនេះ អាស៊ានត្រូវការជាចាំបាច់ទាំងការតភ្ជាប់ឌីជីថលនិងមនុស្សបច្ចេកវិទ្យា (E-people)។ រដ្ឋមន្ត្រីទូរគមនាគមន៍ និងព័ត៌មានវិទ្យាអាស៊ាន មានតួនាទីយ៉ាងសំខាន់ក្នុងការបង្កើតសហគមន៍សេដ្ឋកិច្ចឌីជីថលអាស៊ាន។ ម្យ៉ាងវិញទៀត ខ្ញុំបានកត់សម្គាល់ឃើញថា កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីទូរគមនាគមន៍និងព័ត៌មានវិទ្យាអាស៊ានលើកទី១៧ នេះមានកំណត់ប្រធានបទយ៉ាងច្បាស់អំពីអនាគតនៃអាស៊ានគឺ "***សន្តិភាព និងកម្មញ្ញភាពវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន៖ ឆ្ពោះទៅសហគមន៍មួយដែលត្រូវបានធ្វើសមាហរណកម្មឌីជីថល***"។ ប្រធានបទនេះគឺជាប្រធានបទសំខាន់បំផុត និងមានចរិក-លក្ខណៈបច្ចុប្បន្នភាព ខណៈដែលប្រទេសនិងប្រជាជាតិនានាក្នុងតំបន់បានកំណត់គោលដៅប្រែក្លាយជាប្រទេសផ្អែកលើសេដ្ឋកិច្ចឌីជីថល ដោយបង្កើនការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលដើម្បីជំរុញកំណើនសេដ្ឋកិច្ច។ ក្នុងបរិបថដែលសេដ្ឋកិច្ចឌីជីថលត្រូវបានបញ្ជ្រាបទៅក្នុងគ្រប់វិស័យ និងបានក្លាយជាសមាសភាពដ៏សំខាន់នោះ វិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាននៅតែបន្តមានតួនាទីសំខាន់ក្នុងការផ្លាស់ប្តូរសង្គម និងសមិទ្ធិផលនៃភាពរុងរឿងប្រជាជនអាស៊ាន និងការបើកចំហរឱកាសថ្មីៗដើម្បីសម្រេចនូវសហគមន៍ប្រកបដោយសមាហរណកម្មអាស៊ាន។ ជាមួយនឹងទិសដៅសម្រាប់អនាគតនេះ ខ្ញុំសូមចូលរួមចែករំលែកទស្សនៈរបស់ខ្ញុំពាក់ព័ន្ធនឹងតួនាទីនៃកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីទូរគមនាគមន៍ និងព័ត៌មានវិទ្យាអាស៊ាន សម្រាប់ជាគំនិតពិចារណាដូចខាងក្រោម៖

***ទី១.*** ដើម្បីបោះជំហានទៅមុខទាំងអស់គ្នាក្នុងការអនុវត្តភារកិច្ចរបស់យើងជាមួយនឹងការប្តេជ្ញាចិត្តឆ្ពោះទៅរកគោលដៅរួមមួយនៃការកសាងសហគមន៍អាស៊ានដែលមានវាសនាតែមួយ អាស៊ានត្រូវលើកកម្ពស់និងជំរុញការតភ្ជាប់ក្នុងតំបន់ (ការតភ្ជាប់ដោយផ្ទាល់ និងចំណុចផ្លាស់ប្តូរចរាចរអ៊ិនធឺណិត) ដោយធ្វើការសម្របសម្រួលនិងរកដំណោះស្រាយលើបញ្ហាភូមិសាស្ត្រ និងការភ្ជាប់រវាងបណ្តាប្រទេសកំពុងអភិវឌ្ឍមានរបាំង (landlocked countries) ទាំងអស់ឆ្ពោះទៅកាន់ឱកាសក្នុងតំបន់និងសកល តាមរយៈការចូលប្រើប្រាស់បណ្តាញខ្សែកាប្លិ៍អុបទិកអន្តរជាតិ រួមមានខ្សែកាប្លិ៍ក្រោមបាតសមុទ្រក្នុងតំបន់ និងការកាត់បន្ថយគម្លាតឌីជីថល។

***ទី២.*** ខ្ញុំសូមធ្វើការគូសបញ្ជាក់ថា ការកាត់បន្ថយ "គម្លាតឌីជីថល" គឺជាកង្វល់ដ៏ធំសម្រាប់មនុស្សរាល់គ្នានៅជុំវិញពិភពលោកនាពេលថ្មីៗនេះ និងក៏ជាបញ្ហាស្នូលសម្រាប់អាស៊ានក្នុងការអភិវឌ្ឍសមត្ថភាពឌីជីថលជាមួយនឹងក្របខណ្ឌបទប្បញ្ញត្តិពាក់ព័ន្ធ ដែលនឹងគាំទ្រទៅដល់បរិស្ថានថ្មីនេះផងដែរ។ យើងដឹងថាបញ្ហាប្រឈមនេះនៅតែមាននៅឡើយ។ ទោះជាយ៉ាងណាក៏ដោយ ជាមួយនឹងការខិតខំព្យាយាមរបស់យើងទាំងអស់គ្នា ខ្ញុំជឿជាក់ថា យើងនឹងអាចដោះស្រាយបញ្ហាប្រឈមនេះ និងអាចធានានូវបរិយាប័ន្នឌីជីថល ដែលប្រជាជនគ្រប់រូបអាចទទួលនូវអត្ថប្រយោជន៍ប្រកបដោយភាពរីករាយនិងឱកាសនៃការតភ្ជាប់ទាំងរូបវន្តនិងជាអរូបី។ ហេតុដូចនេះ ខ្ញុំសូមអំពាវនាវឡើងវិញនូវការប្តេជ្ញាចិត្តខ្លាំងក្លាមួយរបស់ឯកឧត្តម លោកជំទាវ លោក លោកស្រី ដើម្បីឱ្យសម្រេចនូវគោលដៅដែលបានកំណត់ដោយផែនការមេ

វិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានអាស៊ានឆ្នាំ2020 និងផែនការ "ការតភ្ជាប់ឆ្នាំ2020" សម្រាប់កំណើន បរិយាប័ន្ន ចីរភាព និងនវានុវត្តន៍ ដើម្បីធានាថាគម្លាតឌីជីថលរបស់យើងនឹងត្រូវកាត់បន្ថយគួរកត់សម្គាល់នៅឆ្នាំ២០២០។

*ទី៣.* យុវជនចំនួនប្រមាណ ១,៥ ពាន់លាននាក់ រស់នៅលើពិភពលោកយើងសព្វថ្ងៃនេះ។ ចំនួនយុវជនដែលរស់នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍នឹងកើនឡើងដល់ចំនួន ៨៩,៥% ត្រឹមឆ្នាំ២០២៥។ ចំនួននៃការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន មានការកើនឡើងគួរឱ្យកត់សម្គាល់ ដែលបានក្លាយជាអាទិភាពរបស់យុវជនទាំងក្នុងតំបន់និងពិភពលោក ដូចជាការទទួលបានការអប់រំ ការងារ និងកាត់បន្ថយភាពក្រីក្រ។ បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានពិតជាអាចបង្កើតនូវបណ្តាញនៃកិច្ចសហការ កិច្ចសន្ទនា និងការផ្លាស់ប្តូរព័ត៌មានក្នុងចំណោមយុវជនដ៏មានប្រសិទ្ធភាព។ ដូច្នេះ តួនាទីរបស់យុវជននៅក្នុងសង្គមព័ត៌មានគឺជាកត្តាសំខាន់មួយ តាមរយៈសមត្ថភាពរបស់ខ្លួន ដើម្បីសិក្សា ដើម្បីប្រើប្រាស់ និងដើម្បីអភិវឌ្ឍបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន និងកម្មវិធីនានា។ បន្ថែមពីនេះ យើងត្រូវយកបញ្ហាយុវជនទៅបញ្ចូលក្នុងគំនិតពិចារណាក្នុងរបៀបវារៈនៃការអភិវឌ្ឍបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានរបស់អាស៊ាន និងគោលនយោបាយបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាននៃរដ្ឋសមាជិកអាស៊ាននីមួយៗ។ យើងគួររៀបចំទុកជាមុន និងចូលរួមយ៉ាងសកម្មនៅក្នុងការកសាងសមត្ថភាពបច្ចេកវិទ្យា ដើម្បីឱ្យស្របទៅនឹងតម្រូវការរបស់ពួកគេ។ ម្យ៉ាងវិញទៀត ខ្ញុំសូមប្រគល់ភារកិច្ចនេះដល់កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីទូរគមនាគមន៍និងព័ត៌មានវិទ្យាអាស៊ាន ឱ្យធ្វើការងារនេះ និងធានាថាយុវជនរបស់យើងត្រូវបានបំពាក់ចំណេះដឹងនិងជំនាញប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានដ៏សមស្រប រួមមានសមត្ថភាពធ្វើការវិភាគ និងវាយតម្លៃព័ត៌មាន ក្នុងវិធីមួយប្រកបដោយនវានុវត្តនិងការច្នៃប្រឌិត ដើម្បីចែករំលែកជំនាញ និងចូលរួមរបស់ពួកគេនៅក្នុងសង្គមព័ត៌មាន។

*ទី៤.* យើងបានទទួលស្គាល់ថាការកើនឡើងការវាយប្រហារតាមបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានមានភាពស្មុគស្មាញកាន់តែខ្លាំងឡើងៗ។ ការវាយប្រហារនេះ បង្កភាពភ័យខ្លាចមិនត្រឹមតែចំពោះប្រតិបត្តិការធុរកិច្ចនិងទ្រព្យសម្បត្តិរបស់ក្រុមហ៊ុននោះទេ ប៉ុន្តែចំពោះសន្តិសុខជាតិនិងអធិបតេយ្យរបស់ជាតិដែលអាចបណ្តាលឱ្យខាតបង់យ៉ាងខ្លាំងដល់សេដ្ឋកិច្ច និងបានបង្កើតបញ្ហាថ្មីៗជាច្រើនសម្រាប់ការអភិវឌ្ឍជាតិនិងតំបន់របស់យើង។ បញ្ហាសន្តិសុខតាមប្រព័ន្ធអេឡិកត្រូនិកគឺជាបញ្ហាសកលនិងអន្តរយុត្តាធិការ ដូច្នេះហើយយើងមិនត្រឹមតែអភិវឌ្ឍនិងអនុវត្តយុទ្ធសាស្ត្រសន្តិសុខតាមប្រព័ន្ធអេឡិកត្រូនិកតែផ្ទៃក្នុងនោះទេ ប៉ុន្តែយើងក៏ត្រូវកសាងទំនាក់ទំនងរវាងរដ្ឋាភិបាល ដោយរួមបញ្ចូលទាំងភ្នាក់ងារអនុវត្តច្បាប់ ឧស្សាហករ ពាណិជ្ជករ និងអ្នកប្រើប្រាស់នៅក្នុងអាស៊ាន រួមទាំងតួអង្គសហប្រតិបត្តិការផ្សេងទៀតស្តីពីបញ្ហាសន្តិសុខ ដើម្បីប្រឆាំងទល់នឹងការគម្រាមដល់ហេដ្ឋារចនាសម្ព័ន្ធនិងបណ្តាញ, ការបង្កើតអភិក្រមពហុភាគី តាមរយៈការអភិវឌ្ឍអភិក្រមពហុភាគីដោយពង្រឹងសកម្មភាពផ្សព្វផ្សាយអំពីសន្តិសុខតាមប្រព័ន្ធអេឡិកត្រូនិក

ជាពិសេសហេដ្ឋារចនាសម្ព័ន្ធឌីជីថលនិងសេវា។ ក្នុងស្មារតីនេះ ខ្ញុំជឿជាក់ថា កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីទូរគមនាគមន៍និងព័ត៌មានវិទ្យាអាស៊ាន ត្រូវបន្តផ្តោតលើការជំរុញកិច្ចសហប្រតិបត្តិការបន្ថែមទៀតសម្រាប់សម្រេចទៅលើសកម្មភាពផ្សព្វផ្សាយ ដើម្បីសម្របសម្រួលការងាររបស់អ្នកពាក់ព័ន្ធ សំខាន់ៗមន្ត្រីអនុវត្តច្បាប់ នីតិករ និងបុគ្គលផ្សេងៗ ដើម្បីប្រយុទ្ធប្រឆាំងនឹងការវាយប្រហារ និងធ្វើឱ្យប្រសើរឡើងនូវសន្តិសុខតាមប្រព័ន្ធអេឡិកត្រូនិក។ ការចែករំលែកបទពិសោធន៍ និងការបង្កើតវិធីសាស្ត្រអនុវត្តល្អបំផុត ចំពោះសន្តិសុខតាមប្រព័ន្ធអេឡិកត្រូនិក គឺដើម្បីធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពឆ្លើយតប និងចំពោះផែនការគ្រោះមហន្តរាយនៅក្នុងករណីមានការវាយប្រហារតាមប្រព័ន្ធអេឡិកត្រូនិក។

***ឯកឧត្តម លោកជំទាវ លោក លោកស្រី***

ក្រៅពីអាទិភាពខាងលើ យើងនៅមានបញ្ហាប្រឈមជាច្រើនផ្សេងទៀត ដែលត្រូវរួមគ្នាដោះស្រាយ ដើម្បីនាំមកនូវដំណើរការវិវត្ត និងភាពរុងរឿងសម្រាប់ប្រជាជនរបស់យើង។ ដើម្បីធ្វើឱ្យសម្រេចបាន **សហគមន៍សមាហរណកម្មអាស៊ាន**ឌីជីថល ឆ្នាំ២០២០ កិច្ចសហប្រតិបត្តិការនៅកម្រិតរដ្ឋាភិបាលតែឯងមិនទាន់គ្រប់គ្រាន់នៅឡើយទេ។ ទាំងនេះទាមទារនូវការចូលរួមយ៉ាងទូលំទូលាយពីដៃគូពាក់ព័ន្ធនៅគ្រប់កម្រិតទាំងអស់ ជាពិសេសការគាំទ្រ និងការចូលរួមពីវិស័យឯកជន និងប្រជាជនអាស៊ានទាំងមូល។

ជាចុងបញ្ចប់ ខ្ញុំសូមជូនពរឯកឧត្តម លោកជំទាវ គណៈប្រតិភូ លោក លោកស្រីទាំងអស់ទទួលបានជោគជ័យល្អប្រសើរក្នុងការពិភាក្សារបស់ឯកឧត្តម លោកជំទាវ លោក លោកស្រី សម្រាប់ជាអត្ថប្រយោជន៍រួមនៃការបង្កើតសហគមន៍សមាហរណកម្មអាស៊ានឌីជីថល។ ជាថ្មីម្តងទៀត ខ្ញុំសូមជូនពរឱ្យការស្នាក់នៅរបស់ឯកឧត្តម លោកជំទាវ លោក លោកស្រី ប្រកបដោយផាសុកភាពនិងសេចក្តីសុខ និងសង្ឃឹមយ៉ាងមុតមាំថា ឯកឧត្តម លោកជំទាវ លោក លោកស្រី នឹងនាំយកនូវអនុស្សាវរីយ៍មិនអាចបំភ្លេចបានអំពីវប្បធម៌និងសង្គមរបស់ប្រទេសកម្ពុជា ដែលជា "**ព្រះរាជាណាចក្រអច្ឆរិយ**" ត្រឡប់ទៅកាន់ប្រទេសរបស់ខ្លួនវិញ។

ខ្ញុំសូមប្រកាសបើកកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីទូរគមនាគមន៍និងព័ត៌មានវិទ្យាអាស៊ានលើកទី១៧ ជាផ្លូវការចាប់ពីពេលនេះតទៅ!

***សូមអរគុណ!***